# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣

## ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី



Food and Agriculture Organization of the United Nations

50x2030 DATA-SMART AGRICULTURE

**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# ការចិញ្ចឹមបសុសត្វ និងបសុបក្សី

នៅក្នុងប្រទេសកម្ពុជា ការចិញ្ចឹមបសុសត្វ និងបសុបក្សី គឺជាសកម្មភាពកសិកម្មដ៏សំខាន់មួយដែលធ្វើឡើងដោយគ្រួសារកសិកម្ម ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងផ្តល់ ប្រាក់ចំណូលដល់គ្រួសារនៅទីជនបទ។ ក្នុងចំណោមគ្រួសារកសិកម្មសរុបនៅប្រទេសកម្ពុជា មានគ្រួសារចូលរួមសកម្មភាពចិញ្ចឹមបសុសត្វ/បសុបក្សី/សត្វល្អិត ចំនួន ១ ៤០៤ ៩៥០គ្រួសារ។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ បានបែងចែកបសុសត្វជាពីរ គឺប្រភេទបសុសត្វធំ (គោ ក្របី និងសេះ) និងប្រភេទបសុសត្វតូច (ជ្រូក និងពពែ)។

**តារាងទី៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ និងបសុបក្សី (គិតជាពាន់)**

| ប្រទេសកម្ពុជា (ចំនួនគ្រួសារ គិតជាពាន់) | | | |
|---|---|---|---|
| សរុប | បសុសត្វធំ (គោ ក្របី សេះ) | បសុសត្វតូច (ជ្រូក ពពែ) | បសុបក្សី (មាន់ ទា ត្រចៀកកាំ) |
| ១ ៤០៥ | ៧៤២ | ៩៧ | ១ ១២៣ |

គ្រួសារកសិកម្មដែលបានចូលរួមធ្វើសកម្មភាពចិញ្ចឹមសត្វបានបង្ហាញថា បសុសត្វធំ និងបសុបក្សីភាគច្រើន គឺមាននៅតំបន់វាលទំនាប ដោយសារតំបន់នេះមានអំណោយផលល្អសម្រាប់សកម្មភាពចិញ្ចឹមសត្វ ហើយបន្ទាប់ពីនេះ គឺនៅតំបន់បឹងទន្លេសាប និងតំបន់ភ្នំនិងខ្ពង់រាប ខណៈដែលតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារដែលចិញ្ចឹមសត្វតិចជាងគេ។ ទោះជាយ៉ាងនេះក្តី បសុសត្វប្រភេទតូច ត្រូវបានគេចិញ្ចឹមច្រើនគេនៅតំបន់បឹងទន្លេសាប និងតិចជាងគេនៅតំបន់ឆ្នេរសមុទ្រ។

រូបទី ៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វនិងបសុបក្សី ចែកតាមតំបន់ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

# បសុសត្វធំ




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## សត្វគោ

ជាទូទៅ បសុសត្វប្រភេទធំដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេ គឺ គោ ដែលមានប្រមាណជា ៣ ១៨៣ ០០០ ក្បាល នៅទូទាំងប្រទេសកម្ពុជា។ តំបន់វាលទំនាប គឺជាតំបន់មួយដែលមានការចិញ្ចឹមគោច្រើនជាងគេ (១ ២៨៣ ០០០ក្បាល) ហើយជាបន្តបន្ទាប់ គឺតំបន់បឹងទន្លេសាប (១ ១៨១ ០០០ក្បាល) តំបន់ភ្នំ និងខ្ពង់រាប (៥៦១ ០០០ក្បាល) និងតំបន់ឆ្នេរសមុទ្រដែលជាតំបន់មានការចិញ្ចឹមគោតិចជាងបំផុត (១៥៩ ០០០ក្បាល) បើប្រៀបធៀបទៅនឹងតំបន់ទាំងបួន។

រូបទី ៣.២. ចំនួនគ្រួសារនិងចំនួនគោដែលបានចិញ្ចឹម ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅទូទាំងប្រទេសកម្ពុជា គ្រួសារដែលចិញ្ចឹមគោមានចំនួនគោជាមធ្យមប្រមាណ ៤,៦ ក្បាល ក្នុងមួយគ្រួសារ។ គ្រួសារកសិកម្មភាគច្រើនចិញ្ចឹមគោចាប់ពី ៣ទៅ៩ក្បាល (៣៩៧ ០០០គ្រួសារ) ខណៈដែលចំនួនពី ១ ទៅ ២ក្បាល មានចំនួន ២២៤ ០០០ គ្រួសារ និងចាប់ពី ១០ ទៅ ១៩ក្បាល មានចំនួន ៥៣ ០០០ គ្រួសារ និងមានតែ ១១ ០០០ គ្រួសារប៉ុណ្ណោះ ដែលបានរាយការណ៍ថាមានការចិញ្ចឹមគោច្រើនជាងចំនួន ២០ក្បាល។

រូបទី ៣.៣. ចំនួនគ្រួសារកសិកម្មចិញ្ចឹមគោ ចែកតាមចំនួនគោ នៅប្រទេសកម្ពុជាឆ្នាំ២០២៣ (គិតជាពាន់)




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើន គឺជាគោញី ដែលមានចំនួន ១,៧ លានក្បាល (ប្រមាណជា ៥៣,៥%) មានអាយុលើសពី២ឆ្នាំ ខណៈដែលគោឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចតួចជាងគេ។

រូបទី ៣.៤. ចំនួនគោ ចែកតាមភេទ និងអាយុនៅប្រទេសកម្ពុជាឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ចំនួនគោដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជច្រើនលើសលុបជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប ចំនួនគោដែលបានកើតពីមេពូជមានច្រើនជាងគេ (២៥៤ ០០០ក្បាល) បន្ទាប់មក គឺតំបន់វាលទំនាប (២៤៥ ០០០ក្បាល) តំបន់ភ្នំនិងខ្ពង់រាប (១២៨ ០០០ក្បាល) និងតិចជាគេនៅតំបន់ឆ្នេរសមុទ្រ (២៦ ០០០ក្បាល)។

រូបទី ៣.៥. ចំនួនគោបានកើតនិងទិញ ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

បម្រែបម្រួលសត្វ គឺជាការកែប្រែប្រួលនូវចំនួនសត្វចិញ្ចឹមតាមគ្រួសារកសិកម្មក្នុងរយៈពេល១២ខែកន្លងមក ដូចជាការលក់ ការស្លាប់ សម្លាប់យកសាច់ ឬឱ្យទៅអ្នកផ្សេងជាដើម។ ការប្រែប្រួលចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មនូវទូទាំងប្រទេសក្នុងរយៈពេល១២ខែកន្លងមក បានបង្ហាញថា ភាគច្រើនគឺការចិញ្ចឹមលក់រស់ (៥៦០ ០០០ក្បាល) ហើយបន្ទាប់មក គឺការស្លាប់ដោយធម្មជាតិឬដោយជំងឺមាន ៩៧ ០០០ក្បាល ផ្តល់ជាអំណោយមាន ៦ ០០០ក្បាល ខណៈដែលការសម្លាប់យកសាច់មានចំនួន ៥ ០០០ក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមគោនៅស្រុករលាប្អៀរខេត្តកំពង់ឆ្នាំង*

## សត្វក្របី

គ្រួសារដែលប្រកបរបរកសិកម្មដែលមានចិញ្ចឹមក្របីនៅទូទាំងប្រទេសកម្ពុជាបានរាយការណ៍ថា មានក្របីសរុបប្រមាណ ៣៣៥ ០០០ក្បាល។ នៅតំបន់វាលទំនាបមានក្របីច្រើនជាងគេ (១៤៧ ០០០ក្បាល) បន្ទាប់មកតំបន់បឹងទន្លេសាបមានចំនួន ១៣២ ០០០ក្បាល ហើយតំបន់ភ្នំនិងខ្ពង់រាប ដែលមានប្រមាណ ៤៣ ០០០ក្បាល ចំណែកឯចំនួនក្របីនៅតំបន់ឆ្នេរសមុទ្រ មិនបានបង្ហាញ។




រូបទី ៣.៧. ចំនួនគ្រួសារនិងចំនួនក្របីដែលបានចិញ្ចឹម ចែកតាមតំបន់ ឆ្នាំ២០២៣

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅទូទាំងប្រទេសកម្ពុជា ចំនួនសត្វក្របីជាហ្វូងគិតជាមធ្យម ប្រមាណ ៥,៣ក្បាល ក្នុង១គ្រួសារ។ គ្រួសារចិញ្ចឹមក្របីភាគច្រើនមានពី ៣ទៅ៩ក្បាល មានចំនួន ៣៩ ០០០គ្រួសារ ហើយបន្ទាប់មក គឺពី ១ទៅ២ក្បាល មានចំនួន ១៥ ០០០គ្រួសារ និងមានតែ ៦ ០០០គ្រួសារ ប៉ុណ្ណោះដែលបានរាយការណ៍ថាមានចិញ្ចឹមក្របីចាប់ពី ១០ក្បាល ឡើងទៅ។




រូបទី ៣.៨. ចំនួនគ្រួសារកសិកម្មចិញ្ចឹមក្របី ចែកតាមចំនួនក្របី នៅប្រទេសកម្ពុជាឆ្នាំ២០២៣ (គិតជាពាន់)

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ចំនួនក្របីដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើនគឺជាក្របីញី ដែលប្រមាណជា ៥១% មានអាយុលើសពី២ឆ្នាំ ចំណែកគ្រួសារកសិកម្មចិញ្ចឹមក្របីឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចជាងគេ។

រូបទី ៣.៩. ចំនួនក្របី ចែកតាមភេទនិងអាយុ នៅប្រទេសកម្ពុជាឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

# បសុសត្វតូច

## សត្វជ្រូក

ប្រមាណជា ៩៧ ០០០គ្រួសារ នៃគ្រួសារកសិកម្មបានចិញ្ចឹមជ្រូកនៅទូទាំងប្រទេសកម្ពុជា។ គ្រួសារនៅតំបន់បឹងទន្លេសាបមានការចិញ្ចឹមជ្រូកច្រើនជាងគេ (៣៩ ០០០គ្រួសារ) បន្ទាប់មក គឺ តំបន់វាលទំនាប (៣០ ០០០គ្រួសារ) តំបន់ភ្នំនិងខ្ពង់រាប (១៩ ០០០ក្បាល) និងនៅតំបន់ឆ្នេរសមុទ្រមានគ្រួសារចិញ្ចឹមជ្រូកតិចជាងគេ (៩ ០០០គ្រួសារ)។

រូបទី ៣.១០. ចំនួនគ្រួសារ និងចំនួនជ្រូកដែលបានចិញ្ចឹម ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅទូទាំងប្រទេសកម្ពុជា ចំនួនជ្រូកដែលបានចិញ្ចឹមគិតជាមធ្យមក្នុងមួយគ្រួសារ គឺ ៩,៥ ក្បាល។ គ្រួសារកសិកម្មដែលចិញ្ចឹមជ្រូកចន្លោះពី ១ទៅ២ក្បាល មានចំនួន ៣០ ០០០គ្រួសារ ចាប់ពី ៣ទៅ៩ក្បាល មានចំនួន ២៨ ០០០ គ្រួសារ ពី១០ទៅ១៩ ក្បាល មានចំនួន ២១ ០០០គ្រួសារ និងគ្រួសារដែលចិញ្ចឹមជ្រូកចាប់ពី ២០ ក្បាលឡើងទៅ មានចំនួន ១៤ ០០០ គ្រួសារ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ជ្រូកដែលចិញ្ចឹមក្នុងគ្រួសារភាគច្រើនជាសត្វដែលមានអាយុតិចជាង១ឆ្នាំ (ប្រមាណ ៤៦៧ ០០០ ក្បាល ឬ ៥១% នៃជ្រូកទាំងអស់)។ លើសពីនេះ ជ្រូកចំនួន ៥៦៧ ០០០ក្បាល ឬប្រមាណ ៦២% នៃជ្រូកសរុបគឺ ជាជ្រូកញី។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ចំនួនជ្រូកដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជជាជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប ចំនួនជ្រូកដែលបានកើតពីមេពូជមានច្រើនជាងគេ (៣៤១ ០០០ក្បាល) បន្ទាប់មក គឺតំបន់វាលទំនាប (២៥១ ០០០ក្បាល) តំបន់ឆ្នេរសមុទ្រ (៩៦ ០០០ក្បាល) និងតិចជាងគេនៅតំបន់ភ្នំ និងខ្ពង់រាប (៨០ ០០០ក្បាល)។

រូបទី ៣.១៣. ចំនួនជ្រូកបានកើតនិងទិញ ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

# បសុបក្សី




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ការប្រមូលទិន្នន័យអង្កេតកសិកម្មត្រូវបានប្រមូលព័ត៌មានពីការចិញ្ចឹមបសុបក្សីផងដែរ។ នៅក្នុងតារាងទិន្នន័យលទ្ធផលដែលបានផ្សព្វផ្សាយអំពីបសុបក្សី មានដូចជា មាន់ ទា និងក្ងាន ហើយរបាយការណ៍នេះផ្តោតតែលើការចិញ្ចឹមបសុបក្សីដែលសំខាន់ជាងគេ គឺសត្វមាន់ និងទា។



## សត្វមាន់

មាន់ គឺជាប្រភេទបសុបក្សីដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេមានចំនួន ១ ១០៤ ០០០ គ្រួសារ ស្មើនឹង ២៨លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមមាន់ច្រើនជាងគេចំនួន ៤២៧ ០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាបមាន ៤១៥ ០០០គ្រួសារ ហើយតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១៦១ ០០០គ្រួសារ និងតំបន់ឆ្នេរសមុទ្រមានចំនួន ១០១ ០០០គ្រួសារ ។ ចំនួនមាន់ជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ២៦ក្បាល។

រូបទី ៣.១៤. ចំនួនគ្រួសារកសិកម្មចិញ្ចឹមមាន់ ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅតំបន់វាលទំនាប បានបង្ហាញថាមានចំនួនមាន់ច្រើនជាងគេសរុបប្រមាណ ១១លានក្បាល។ នៅតំបន់បឹងទន្លេសាបមានចំនួន ១០លានក្បាល តំបន់ភ្នំ និងខ្ពង់រាបមានចំនួន ៣,៩លានក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួន ៣,៣លានក្បាល។

រូបទី ៣.១៥. ចំនួនមាន់សរុប ចែកតាមតំបន់ ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ការចិញ្ចឹមមាន់របស់គ្រួសារកសិកម្មគឺបានមកពីការកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញមាន់ចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាបមានមាន់កើតកូនបន្តពូជច្រើនជាងគេចំនួនប្រមាណ ១៣,១លានក្បាល

បន្ទាប់មកនៅតំបន់បឹងទន្លេសាប មាន ១២,៨លានក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាបមាន ៣,០ លានក្បាល និងតំបន់ឆ្នេរសមុទ្រមាន ៣,០លានក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ចំពោះបម្រែបម្រួលសត្វមាន់ទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក ដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មបានបង្ហាញថាភាគច្រើន គឺស្លាប់ដោយសារធម្មជាតិ និងជំងឺឆ្លងផ្សេងៗដែលមានចំនួន ១៥លានក្បាលនៅឆ្នាំ២០២៣។ ការសម្លាប់យកសាច់ចំនួន ១០,៦លានក្បាល ចិញ្ចឹមលក់រស់មានចំនួន ៧,៧លានក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*



## សត្វទា

ទា គឺជាប្រភេទបសុបក្សីទី២ ដែលគ្រួសារកសិកម្មភាគច្រើនបានចិញ្ចឹមមានចំនួន ១៨៥ ០០០ គ្រួសារ ស្មើនឹង ១២,១លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមទាច្រើនជាងគេចំនួន ៨៣ ០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាបមាន ៦១ ០០០គ្រួសារ ហើយតំបន់ឆ្នេរសមុទ្រ មានចំនួន ២៥ ០០០គ្រួសារ និង តំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១៦ ០០០គ្រួសារ។ ចំនួនទាជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ៦៥ក្បាល ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅតំបន់បឹងទន្លេសាប មានចំនួនទាសរុបប្រមាណ ៥,៤លានក្បាល នៅតំបន់វាលទំនាប មានចំនួនប្រហែល ៥,១លានក្បាល និងនៅតំបន់ភ្នំ និងខ្ពង់រាបមានទាចំនួនប្រហែល ៣៩១ ០០០ក្បាល។ ហើយចំនួនទានៅតំបន់ឆ្នេរសមុទ្រ មិនបានបង្ហាញ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

បម្រែបម្រួលសត្វទាក្នុងរយៈពេល១២ ខែកន្លងមក ការចិញ្ចឹមទារបស់គ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញទាចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប មានទាកើតកូនបន្តពូជច្រើនជាងគេចំនួន ១,២លានក្បាល បន្ទាប់មកគឺតំបន់វាលទំនាបមាន ១,០លានក្បាល ហើយតំបន់ឆ្នេរសមុទ្រ មានប្រមាណ ២៦២ ០០០ក្បាល និងនៅតំបន់ភ្នំ និងខ្ពង់រាប មាន ១៧៥ ០០០ក្បាល តិចជាងគេ។



រូបទី ៣.២០. ចំនួនទាបានកើត ចែកតាមតំបន់ ឆ្នាំ២០២៣

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

បម្រែបម្រួលសត្វទាទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក នៃការចិញ្ចឹមទារបស់គ្រួសារកសិកម្ម បានបង្ហាញថា ការលក់រស់មានចំនួនប្រមាណ ៣,៦ លានក្បាល ហើយចំនួន ១,៧ លានក្បាល បានស្លាប់ដោយសារធម្មជាតិ ជំងឺ និងជំងឺឆ្លងផ្សេងៗ និងមាន ៨៤៩ ០០០ក្បាល ត្រូវបានសម្លាប់យកសាច់។



រូបទី ៣.២១. ចំនួនបម្រែបម្រួលទា ប្រទេសកម្ពុជាឆ្នាំ២០២៣

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ការថែទាំសត្វ

ការចាក់វ៉ាក់សាំងបង្ការជំងឺ លើបសុសត្វធំ និងតូច របស់គ្រួសារកសិកម្មបានរាយការណ៍ថា មានចំនួនច្រើនលើសលុបជាងសេវាព្យាបាលសត្វផ្សេងៗ រួមទាំងការព្យាបាល និងថ្នាំបង្ការផ្សេងៗ។ ទោះជាការចាក់វ៉ាក់សាំងបង្ការជំងឺលើបសុបក្សីរបស់គ្រួសារកសិកម្ម មានចំនួនតិចជាងការព្យាបាលផ្សេងៗ តែការចាក់វ៉ាក់សាំងបង្ការជំងឺលើបសុបក្សីចំនួនច្រើនទី២ ក្នុងចំណោមសេវាព្យាបាលសត្វផ្សេងៗ។

រូបទី ៣.២២. ការថែទាំសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជាឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ប្រភពទឹកសំខាន់ៗ

អណ្តូងស្នប់ គឺជាប្រភពទឹកសំខាន់ទាំងក្នុងរដូវប្រាំង និងរដូវវស្សាដែលផ្តល់ដោយគ្រួសារកសិកម្ម ដល់បសុសត្វរបស់ពួកគេ។ ទំនប់ទឹក ទឹកអណ្តូងជីក និងការទិញទឹកពីអ្នកផ្គត់ផ្គង់ឯកជន ជាប្រភពទឹកសំខាន់បន្ទាប់សម្រាប់ផ្តល់ដល់សត្វចិញ្ចឹម។ ចំណែកឯទឹកភ្លៀងគឺជាប្រភពទឹកសំខាន់ទី៤ សម្រាប់រដូវវស្សា។



រូបទី ៣.២៣. ប្រភពទឹកសំខាន់សម្រាប់ផ្តល់ឱ្យបសុសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជាឆ្នាំ២០២៣

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

សម្រាប់បសុបក្សី អណ្តូងស្នប់ក៏ជាប្រភពទឹកសំខាន់ជាងគេទាំងក្នុងរដូវប្រាំង និងរដូវវស្សាដែលផ្តល់ដោយគ្រួសារកសិកម្ម។ ទឹកភ្លៀង គឺជាប្រភពទឹកសំខាន់ទី៥ សម្រាប់រដូវវស្សា។



រូបទី ៣.២៤. ប្រភពទឹកសំខាន់សម្រាប់ផ្តល់ឱ្យបសុបក្សីរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជាឆ្នាំ២០២៣

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ចំណីសត្វ

ការអោយសត្វស៊ីចំណីតាមធម្មជាតិត្រូវបានអនុវត្តភាគច្រើន ក្នុងចំនោមគ្រួសារកសិកម្មទាំងលើបសុសត្វ និងបសុបក្សី ខណៈការផ្តល់ចំណីសុទ្ធត្រូវបានអនុវត្តតិចតួចបំផុត។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

កាកសំណល់ផ្ទះបាយ ដូចជាកន្ទក់ ឬបាយស្រា ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុបក្សីដោយគ្រួសារកសិកម្ម ខណៈដែលដំណាំ/ស្មៅសម្រាប់សត្វ និងចំណីកិន (Concentrate) ជាជម្រើសបន្ទាប់។ ចំណែកឯ សំណល់ដំណាំដូចជាចំបើង ឬសំបកពោត ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុសត្វដោយគ្រួសារកសិកម្ម ។ ចំណែកឯ ផលិតផលកសិឧស្សាហកម្ម ដូចជាកាកគ្រាប់ប្រេង ឬកាកស្រាសាឡី (កាកប៊ីយែរ) គឺត្រូវបានប្រើប្រាស់តិចតួចជាងគេទាំងលើបសុសត្វ និងបសុបក្សី។

រូបទី ៣.២៦. ប្រភេទចំណីសត្វផ្តល់ឱ្យសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជា ឆ្នាំ២០២៣




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*